

គ្រងរាជ្យលើទឹកជំនន់



លោក ដេរេក ព្រីនស៍ មានពាក្យមួយសម្រាប់អ្នកពីព្រះបន្ទូល។

> “ព្រះយេហូវ៉ាទ្រង់បានគង់នៅវេលាជំនន់លោកីយ អើ
> ព្រះយេហូវ៉ាទ្រង់គង់ជាព្រះមហាក្សត្រ នៅអស់កល្បជានិច្ច
> ព្រះយេហូវ៉ាទ្រង់នឹងចំរើនកំឡាំងដល់រាស្ត្រទ្រង់
> ព្រះយេហូវ៉ាទ្រង់នឹងប្រទានពរដល់រាស្ត្រទ្រង់ឲ្យបានសេចក្ដី
> សុខសាន្តគ្រាណា។” (ទំនុកដំកើង 29:10-11 ពគប)

នៅទីនោះ អ្នកនិពន្ធទំនុកតម្កើងបង្ហាញថា
ព្រះអម្ចាស់ជាស្តេចដ៏មានឫទ្ធានុភាព ដែលគង់លើបល្ល័ង្ករបស់ទ្រង់។
ទ្រង់គ្រងរាជ្យលើទឹកជំនន់
និងលើរលកសមុទ្រដ៏ខ្លាំងក្លាដែលកំពុងបក់បោក។ សមុទ្រនៅទីនេះ
បង្ហាញអំពីកម្លាំងដ៏ធំធេងដែលត្រូវបានបញ្ចេញក្នុងចក្រវាល
ដែលអាចគំរាមកំហែងដល់ជីវិតរបស់យើង
ហើយជាកម្លាំងដែលយើងមិនអាចគ្រប់គ្រងបាន។ ប៉ុន្តែ
អ្នកនិពន្ធទំនុកតម្កើងរំលឹកយើងថា លើកម្លាំងទាំងនោះ
មានស្តេចមួយអង្គ ដែលគង់លើបល្ល័ង្ក គឺព្រះអម្ចាស់។

នៅកន្លែងផ្សេងទៀត អ្នកនិពន្ធទំនុកតម្កើងនិយាយថា
ពេលដែលយើងថ្វាយការសរសើរតម្កើងដល់ព្រះអម្ចាស់
នោះយើងតាំងទ្រង់ជាស្តេច។ យើងទទួលស្គាល់ទ្រង់ថាជាស្តេច
ហើយបន្ទាប់មក ទ្រង់ធ្វើការជាស្តេចសម្រាប់យើង។ ដូច្នេះ
ពេលយើងទទួលស្គាល់ថា ព្រះអម្ចាស់គ្រងរាជ្យលើទឹកជំនន់
ហើយពេលយើងថ្វាយការសរសើរតម្កើងដល់ទ្រង់
នោះទ្រង់ឆ្លើយតបតាមវិធីពីរយ៉ាង៖
ទ្រង់ប្រទានកម្លាំងដល់រាស្ត្ររបស់ទ្រង់
ហើយទ្រង់ប្រទានពរជាសន្តិភាពដល់រាស្ត្ររបស់ទ្រង់។ នៅទីបំផុត
កម្លាំងដែលនឹងជួយឲ្យយើងឆ្លងកាត់ថ្ងៃនៃសម្ពាធ
គឺជាកម្លាំងដែលមកពីព្រះអម្ចាស់។

“អ្នកដែលរង់ចាំព្រះយេហូវ៉ា នឹងមានកម្លាំងឡើងវិញ”។
ហើយនៅកណ្តាលសម្ពាធទាំងអស់
ព្រះជាម្ចាស់ប្រទានពរដល់រាស្ត្ររបស់ទ្រង់នូវសន្តិភាព។
សន្តិភាពមិនអាស្រ័យលើកាល:ទេស:ខាងក្រៅទេ
ប៉ុន្តែអាស្រ័យលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះអម្ចាស់
ដែលគង់លើទឹកជំនន់។

: WD-WFTW-030-KHM
: 12 Mar 2026
: derekprince.com/km/resources

© 1970 — Derek Prince Ministries - International®


«ព្រះនៅតែព្រះសណ្ដាប់ជានិច្ច ។
ការសារភាព
និងការលះបង់អំពើបាបរបស់យើង
ជាច្រក
ផ្លូវដើម្បីត្រឡប់ទៅកាន់ទ្រង់វិញ ។»
derekprince.com/km/resources
Cut here to use as a bookmark